ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខ : ៩៦៩៩ អជ៣.អក.អ៥

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ផ្លាស់ប្តូរ តម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្តាញបង្កលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី៣០ ខែតុលា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៦ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងលេខ ប.ត046 ស្ថិតនៅតាមបណ្តោយមហាវិថីព្រះមុនីវង្ស ក្នុងសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា (២)តំបន់ភ្លើងលេខ ប.ត104 ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ ក្នុងភូមិឃ្លាំងសាំង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ (៣)តំបន់ភ្លើងលេខ P680,P681 ស្ថិតនៅក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (៤)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវវេងស្រេង ចាប់ពីភូមិឫស្សី ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រហូតដល់ភូមិត្រពាំងថ្លឹង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

២. ថ្ងៃសុក្រទី៣១ ខែតុលា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី :(១)តំបន់ភ្លើងលេខ ប.ត153 ស្ថិតនៅភូមិបុរី១០០ខ្នង ក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ (២) តំបន់ភ្លើងលេខ P551 ស្ថិតនៅភូមិល្វា ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ (៣)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិព្រៃជីសាក់ ភូមិអង្គកែវ ភូមិព្រៃព្រីង ភូមិព្រៃទា ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ និង (៤)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជើងឯក ចាប់ពីភូមិសំបួរ ក្នុងសង្កាត់ដង្កោ រហូតដល់ភូមិព្រែកប្រណាក់ ក្នុងសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៣. ថ្ងៃសៅរ៍ទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៨ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី : (១)តំបន់ភ្លើងលេខ ប.ត046 ស្ថិតនៅតាមបណ្តោយមហាវិថីព្រះមុនីវង្ស ក្នុងសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិព្រៃសណ្តែក ភូមិព្រៃល្វា ភូមិចោមចៅ ភូមិព្រៃជីសាក់ ភូមិថ្នល់គោល ភូមិជ្រៃកោង ក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

៤.ថ្ងៃអាទិត្យទី០២ ខែវិច្ឆិកា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី:(១)តំបន់ភ្លើងលេខ P766, P1127 ស្ថិតនៅភូមិថ្មី ក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ (២)តំបន់ភ្លើងលេខ P876, P1238 ស្ថិតនៅក្នុងសង្កាត់សំរោង ខណ្ឌព្រែកព្នៅ និង (៣)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិត្រពាំងឈូក ក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភូមិទ្រា ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រួមទាំងតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវវេងស្រេង ចាប់ពីភូមិឫស្សី រហូតដល់ភូមិដំណាក់ធំ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៧ ខែ ១០ ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**